ពុទ្ធបរិស័ទពិត

GENUINE BUDDHISTS

រៀបរៀងដោយ

ខ្ញុំព្រះករុណាអាត្មាភាព ជា សុភាព

BY CHEA SOPHEAP

សម្រាប់ជាធម្មទាន

FOR FREE DISTRIBUTION

ពុទ្ធបរិស័ទពិត

GENUINE BUDDHISTS

រៀបរៀងជាភាសាខ្មែរ	Compiled in Khmer
និងប្រែជាភាសាអង់គ្លេស	and translated into English
ដោយ ជា សុភាព	by ***Chea Sopheap***
សមណសិស្ស	student monk
ជំនាន់ទី ១២	twelve generation
នៃពុទ្ធិកវិទ្យាល័យ	of Buddhist high school
អ៊ឹង ធួង	***Eung Thuong***
ខេត្តបាត់ដំបង	Battambang Province
ប្រទេសកម្ពុជា	Cambodia
បោះពុម្ពលើកទី ១	First Edition
ព.ស.២៥៥៥ គ.ស.២០១១	B.E. 2555; C.E. 2011

អារម្ភកថា

កូនសៀវភៅដ៏តូចមួយក្បាល ដែលលោកអ្នកកំពុងកាន់នៅក្នុងដៃនេះ គឺជាស្នាដៃដំបូងបំផុតមួយរបស់ខ្ញុំ ។ កូនសៀវភៅនេះ ខ្ញុំបានដាក់ឈ្មោះថា **"ពុទ្ធបរិស័ទពិត"** និងត្រូវបានសរសេរជាភាសាខ្មែរម្ខាង និងភាសាអង់គ្លេសម្ខាង ដើម្បីតម្រូវទៅតាមសម័យកាល ព្រោះសម័យនេះ ខ្មែរយើងបានយកភាសាអង់គ្លេស ជាភាសាទីពីរ ។

គោលបំណងរបស់ខ្ញុំ ក្នុងការសរសេរសៀវភៅនេះឡើង គឺចង់ឲ្យពុទ្ធបរិស័ទសិក្សា នូវពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ អំពីធម៌ដែលពុទ្ធបរិស័ទត្រូវសិក្សា និងត្រូវប្រតិបត្តិតាម ដើម្បីក្លាយជាពុទ្ធបរិស័ទដ៏ពិតប្រាកដ ។ ប្រសិនបើពុទ្ធ-បរិស័ទចង់ដឹងថាខ្លួនឯង សព្វថ្ងៃនេះ ជាពុទ្ធបរិស័ទពិតប្រាកដហើយឬនៅ សូមចំណាយពេលខ្លះអាន

FOREWORD

The very little booklet that is now in your hands is my very first achievement. This booklet is named **“Genuine Buddhists”** and written in Khmer language on one side and in English on another side to make it appropriate to the time, because today we, Khmer, accept English as our second language.

My purpose in writing this book is to encourage Buddhists to study the teachings of the Buddha about good qualities that Buddhists must study and practise to become genuine Buddhists. If Buddhists want to scrutinize themselves if they are, these days, genuine Buddhists or not, please take some time to read

ដើម្បីស្វែងយល់ខ្លឹមសារព្រះធម៌ ក្នុងកូនសៀវភៅនេះ ហើយពិចារណាមើលដោយខ្លួនឯងថា: "តើអាត្មាអញជាពុទ្ធបរិស័ទពិតប្រាកដហើយឬនៅ" ។

ចំពោះអត្ថបទធម៌នេះ រូបខ្ញុំផ្ទាល់មិនបានគិតថាជាអត្ថបទដែលល្អឥតខ្ចោះនោះទេ តែវាជាអត្ថបទដែលខ្ញុំធ្វើឡើង ដោយសម្រិតសម្រាំងបំផុត ក្នុងអំឡុងពេលវិស្សមកាល អំពីការសិក្សានៅពុទ្ធិក-វិទ្យាល័យ **អ៊ឹង ជួង** នាពុទ្ធសករាជ ២៥៥៤ ។ ប្រសិនបើ លោកអ្នកចេះដឹងទាំងឡាយណា បានឃើញកំហុសឆ្គង ត្រង់ចំណុចណាមួយ សូមមេត្តាជួយផ្តល់ដំណឹងមកខ្ញុំផង ខ្ញុំរង់ចាំទទួលការរិះគន់ដើម្បីស្ថាបនា ដោយក្តីសោមនស្សរីករាយគ្រប់ពេលវេលា ។

វត្តកំផែង ក្រុងបាត់ដំបង

ថ្ងៃ១៥រោច ខែពិសាខ ព.ស.២៥៥៥

ជា សុភាព

to understand the meaning of the teachings in this booklet and then reflect on by themselves that: *“whether I am a genuine Buddhist or not”.*

As for this Dharma text, I myself do not reckon it as an excellent text, but it is a text that I compiled during my vacation from studying at **Eung Tuong** Buddhist high school in the Buddhist Era 2554. If someone who is well-versed in Buddhist texts finds some mistakes at some points, please kindly inform me. I am looking forward to accepting constructive criticism all the time.

Kampheng Temple, Battambang Town

The 15th of waning moon day of Bisãkha (May) B.E. 2555

Chea Sopheap

សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណា អាត្មាភាពសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជគុណគ្រប់អង្គ និងញាតិញោមពុទ្ធបរិស័ទទាំងអស់ ដែលបានជួយជ្រោមជ្រែងកិច្ចការធម្មទាននេះឲ្យបានសម្រេចដោយជោគជ័យ ទាំងខាងការជួយត្រួតពិនិត្យ និងការជួយជាថវិកាដើម្បីបោះពុម្ព ព្រោះបើមិនមានការជួយជ្រោមជ្រែងទាំងនេះទេ កិច្ចការនេះនឹងមិនអាចសម្រេចបានឡើយ ។

ចំពោះកូនសៀវភៅនេះ បើពុទ្ធបរិស័ទអានហើយឃើញមានចំណុចខ្វះខាត ឬខុសឆ្គងដោយប្រការណានីមួយ និងមានបំណងរិះគន់ដើម្បីស្ថាបនាឲ្យបានរឹងរិតតែល្អសម្រាប់ការបោះពុម្ពលើកក្រោយៗទៀត សូមនិមន្តនិងអញ្ជើញផ្តល់ដំណឹងមកខ្ញុំព្រះករុណា អាត្មាភាព តាមរយៈទូរស័ព្ទលេខ (៨៥៥) ០៨៩ ៦៥ ៦០ ៣០ ឬក៏ Email: *gentleboysp@yahoo.com* ដោយអនុគ្រោះផងចុះ។

សូមអរព្រះគុណ និងសូមអរគុណ!

Acknowledgements

I wish to express my profound thanks to all reverenced monks and laypeople who helped to have this work accomplished successfully –both in proofreading and funding for this publication because, if there is no their help, this work will not be completed.

As for this booklet, if Buddhists have read and found some incomplete meanings or mistakes and attempted to criticize for better construction, please inform me via this phone number (855) 089 65 60 30 or via this Email: *gentleboysp@yahoo.com*.

Thank You!

មាតិកា

ឈ្មោះអត្ថបទ ទំព័រ

សេចក្តីផ្តើម...១
ពុទ្ធបរិស័ទពិត...៤
១.ឧបាសកជាអ្នកមានសទ្ធា.................................៨
អធិប្បាយអំពីសទ្ធា ៤ យ៉ាង...............................១១
២.ឧបាសកជាអ្នកមានសីល...............................១៩
៣.ឧបាសកជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល....២៩
៤.ឧបាសកជាអ្នកជឿតែកម្មមិនជឿមង្គល.........៣៨
៥.ឧបាសកជាអ្នកមិនស្វែងរកទក្ខិណេយ្យ-
បុគ្គលខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យ
តែក្នុងពុទ្ធសាសនា...៤២
តើពុទ្ធសាសនាសម្តែងយ៉ាងណាចំពោះ
ជំនឿខាងព្រលឹង..៥៦

CONTENTS

TEXT NAME PAGE

INTRODUCTION…………………………………....1

GENUINE BUDDHISTS…………………………….4

1. A LAYMAN WHO IS CONFIDENT…………..8

COMMENT ON FOUR KINDS OF *SADDHÃ*…..11

2. A LAYMAN WHO IS MORAL………….………19

3. A LAYMAN WHO DOES NOT ADHERE
TO SUPERSTITIONS……………………………….29

4. A LAYMAN WHO BELIEVES ONLY IN
KAMMA NOT IN SUPERSTITIONS……………....38

5. A LAYMAN WHO DOES NOT SEEK
FOR ONE WHO IS WORTHY OF GIFTS
OUTSIDE BUDDHISM; DOES MERITS
ONLY IN BUDDHISM…………………………..42

HOW DOES BUDDHISM STATE ABOUT
BELIEF IN SOUL…..…………………………….56

សេចក្ដីផ្ដើម

ពាក្យថា **ពុទ្ធបរិស័ទ** ជាពាក្យពីររួមបញ្ចូលគ្នា គឺ **ពុទ្ធ** ជាភាសាបាលី ឬសំស្រ្កឹត ដែលមានន័យថា លោកអ្នកត្រាស់ដឹងធម៌ដែលកំបាំង ដូចយ៉ាងអរិយ-សច្ចៈ ៤ ជាដើម រហូតដល់មគ្គផលនិព្វាន ឬលោកអ្នកភ្ញាក់រឭក គឺមានសតិសម្បជញ្ញៈសព្វៗកាល ឬលោកអ្នករីកពេញទី ដូចជាផ្កាឈូក ដែលរីកគ្រប់ស្រទាប់ គឺមានព្រះហឫទ័យរីក ដោយអំណាចនៃសេចក្ដីបរិសុទ្ធព្រោះកម្ចាត់កិលេសអស់ហើយ ហៅថា **ព្រះសម្មាសម្ពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធបរមគ្រូ ព្រះពុទ្ធជាម្ចាស់** ។ល។ ក៏មាន ដែលយើងរាល់គ្នាស្គាល់ថាជាស្ថាបនិកនៃព្រះពុទ្ធសាសនា និងពាក្យថា **បរិស័ទ** ជាភាសាសំស្រ្កឹត បើជាភាសាបាលីថា **បរិសា** មានន័យថា

ក្រុមមនុស្សដែលមកប្រជុំគ្នា ឬក្រុមមនុស្ស ដែលចូលមកអង្គុយជិត ។ រួមបញ្ចូលគ្នាមក ជាពាក្យថា **ពុទ្ធបរិស័ទ** មានន័យថា ក្រុមមនុស្សដែលមកប្រជុំគ្នាជុំវិញអ្នកត្រាស់ដឹង ឬក្រុមមនុស្សដែលមកអង្គុយជិតអ្នកត្រាស់ដឹងដោយប្រពៃ ។

នៅក្នុងព្រះពុទ្ធសាសនា ពុទ្ធបរិស័ទមាន ៤ ពួកគឺ ភិក្ខុ ភិក្ខុនី ឧបាសក និង ឧបាសិកា ។ នៅប្រទេសខ្មែរយើង ពាក្យថា ពុទ្ធបរិស័ទ ខ្មែរច្រើនតែប្រើដើម្បីហៅពួកគ្រហស្ថដែលកាន់ពុទ្ធសាសនា ចំពោះបព្វជិត ពុំសូវត្រូវបានហៅថាពុទ្ធបរិស័ទទេ ។ ក៏ប៉ុន្តែគប្បីជ្រាបថា ពាក្យថាពុទ្ធបរិស័ទ សំដៅយកទាំងបព្វជិត ទាំងគ្រហស្ថ គឺខាងបព្វជិតមាន ភិក្ខុ និង ភិក្ខុនី ខាងគ្រហស្ថមាន ឧបាសក និង ឧបាសិកា ។

បណ្ដាពុទ្ធបរិស័ទទាំង ៤ ពួកនោះ សូមលើកយកតែពុទ្ធបរិស័ទ ២ ពួកទេមកអធិប្បាយក្នុងកូនសៀវភៅនេះ គឺឧបាសក និងឧបាសិកា ចំណែកឯខាងភិក្ខុ និងភិក្ខុនី មិនបានលើកយកមកអធិប្បាយទេ ព្រោះលោកមានធម៌វិន័យ ដែលត្រូវប្រតិបត្តិតាមច្រើនជាអនេកពេកណាស់ ។ សម្រាប់ឧបាសក និងឧបាសិកាវិញ ក៏មានធម៌វិន័យ ដែលត្រូវបដិបត្តិតាមច្រើនគួរសមដែរ តែក្នុងកូនសៀវភៅនេះ ខ្ញុំនឹងលើកយកចំណុចខ្លះៗ ដែលខ្ញុំយល់ថា មានសារៈប្រយោជន៍ច្រើនដល់ពុទ្ធបរិស័ទ មកអធិប្បាយពន្យល់បន្ថែមតាមសមត្ថភាពចំណេះដឹង និងតាមរយៈការស្រាវជ្រាវបន្ថែមទៀតរបស់ខ្ញុំ ។

ពុទ្ធបរិស័ទពិត

នៅក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ធម្មភាគ (បិដកខ្មែរលេខ ៤៥) ត្រង់ចតុត្ថបណ្ណាសក ឧបាសកវគ្គ ទី ៣ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា:

បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ ឧបាសករតនញ្ច ហោតិ ឧបាសកបទុមញ្ច ឧបាសក-បុណ្ឌរីកញ្ច ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកប ដោយធម៌ ៥ យ៉ាង ឈ្មោះថា **រតនឧបាសក** ផង ឈ្មោះថា **បទុមឧបាសក** ផង ឈ្មោះថា **បុណ្ឌរីកឧ-បាសក** ផង ។ **កតមេហិ បញ្ចហិ** ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ **សទ្ធោ ហោតិ សីលវា ហោតិ អកោតុហលមង្គលិកោ ហោតិ កម្មំ បច្ចេតិ នោ**

មង្គលំ ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ។ គឺឧបាសកជាអ្នកមានសទ្ធា ១ ជាអ្នកមានសីល ១ ជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល ១ ជឿតែកម្ម មិនជឿមង្គល ១ មិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យតែក្នុងពុទ្ធសាសនា ១ ។ **ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ ឧបាសករតនញ្ច ហោតិ ឧបាសកបទុមញ្ច ឧបាសកបុណ្ឌរីកញ្ចាតិ ។** ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា **រតនឧបាសក** ផង ឈ្មោះថា **បទុមឧបាសក** ផង ឈ្មោះថា **បុណ្ឌរីកឧបាសក** ផង ។

តាមព្រះពុទ្ធវចនៈខាងលើនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅ ឧបាសកដែលប្រកបដោយធម៌ ៥ យ៉ាង

*ថាជា **រតនឧបាសក** (ឧបាសកដូចជារតនវត្ថុដ៏មានតម្លៃ មានមាស ពេជ្រជាដើម) ផង ថាជា **បទុ-មឧបាសក** (ឧបាសកដូចជាបទុម គឺផ្កាឈូកក្រហម) ផង ថាជា **បុណ្ឌរីកឧបាសក** (ឧបាសកដូចជាបុណ្ឌរីក គឺផ្កាឈូកស) ផង ។*

*ពាក្យថា **ឧបាសក** ក្នុងទីនេះសំដៅយកពុទ្ធបរិស័ទដែលជា គ្រហស្ថ គឺ ឧបាសក និង ឧបាសិកា ដូចមានវិគ្គហៈនៅក្នុង ឯកសេសសមាស នៃភាសាបាលីជាគ្រឿងបញ្ជាក់ថាៈ **ឧបាសកោ ច ឧបាសិកា ច = ឧបាសកា** មានន័យថា ឧបាសកផង ឧបាសិកាផង ជាឧបាសកទាំងឡាយ ។*

*នៅក្នុងកូនសៀវភៅនេះ ខ្ញុំសូមលើកយកពាក្យថា **ពុទ្ធបរិស័ទពិត** មកប្រើជំនួសពាក្យទាំង ៣ ខាងលើ*

គឺពាក្យថា **រតនឧបាសក បទុមឧបាសក** និង **បុណ្ឌរីកឧបាសក** ដើម្បីឲ្យពុទ្ធបរិស័ទបានជ្រាបយ៉ាងច្បាស់ថា ជា **ពុទ្ធបរិស័ទពិត** ត្រូវតែជាឧបាសកទាំង ៣ ពួកខាងលើនេះ ហើយដើម្បីបានជាឧបាសកទាំង ៣ ពួកខាងលើនេះ ត្រូវតែជាឧបាសក ប្រកបដោយធម៌ទាំងឡាយ ៥ យ៉ាង មានជាឧបាសកជាអ្នកមានសទ្ធាជាដើមនោះឯង ។

១ ឧបាសកជាអ្នកមានសទ្ធា

ពាក្យថា **សទ្ធា** ជាភាសាបាលី មានវិគ្គហៈថា **សទ្ទហតីតិ = សទ្ធា** ប្រែថា ធម្មជាតិណា រមែងជឿ ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **សទ្ធា** ។ សទ្ធាមានគ្រឿងសំគាល់ ដែលហៅថា លក្ខណាទិ-ចតុក្កៈដូច្នេះ :

១.សទ្ទហនលក្ខណា: មានសេចក្តីជឿដល់អារម្មណ៍ល្អជាលក្ខណៈ ។

២.បសាទនរសា: មានសេចក្តីជ្រះថ្លាជាកិច្ច ។

៣.អកាឡុស្សិយបច្ចុប្បដ្ឋានា: មានសេចក្តីមិនល្អក់ស្រអាប់ជាអាការៈប្រាកដ ។

៤.សទ្ធេយ្យវត្ថុបទដ្ឋានា: មានវត្ថុជាទីតាំងនៃការជឿជាហេតុជិត ។

*ក្នុងនាមជាពុទ្ធបរិស័ទ យើងត្រូវជាអ្នកមានជំនឿពិត ជាជំនឿដែលមាំ ជំនឿមិនកម្រើក មិនញាប់ញ័រដោយការអូសទាញអំពីអ្នកដទៃ និងគ្រឿងអូសទាញផ្សេងៗ ។ ពាក្យថា **ជំនឿ** ជាពាក្យខ្មែរ ដែលមានន័យថា ការចុះចិត្តស៊ប់ ដោយយល់ថាពិតទៅតាមសេចក្តីពិត ឬក្នុងរបស់ពិត ។ ក្នុងព្រះពុទ្ធ-សាសនា ពាក្យថា **ជំនឿ** ជាពាក្យដែលប្រែចេញមកពីពាក្យថា **សទ្ធា** ។ **សទ្ធា** គឺជាឈ្មោះរបស់ចេតសិក-ធម៌ម្យ៉ាង ដែលកើតរួមជាមួយនឹងសោភណធម៌គ្រប់ប្រភេទទាំងអស់ ។*

***សទ្ធា** គឺជាគុណជាតិដ៏ល្អ ដែលពុទ្ធបរិស័ទត្រូវចម្រើនឲ្យបានច្រើនក្នុងសន្តាន នៅក្នុងជីវិតប្រចាំថ្ងៃពោលគឺ ពុទ្ធបរិស័ទត្រូវជាអ្នកប្រាថ្នាចម្រើនសទ្ធា*

ឲ្យដូចជា ប្រាថ្នាចង់បានគ្រាប់ពេជ្រដ៏មានតម្លៃដូច្នោះដែរ ។

សទ្ធាមាន ៤ យ៉ាងគឺ:

១. **កម្មសទ្ធា** ការជឿកម្ម ។

២. **វិបាកសទ្ធា** ការជឿផលរបស់កម្ម ។

៣. **កម្មស្សកតាសទ្ធា** ការជឿថាសត្វទាំងឡាយមានកម្មដែលខ្លួនធ្វើហើយជារបស់ខ្លួន ។

៤. **តថាគតពោធិសទ្ធា** ការជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគត ។

អធិប្បាយអំពីសទ្ធា ៤ យ៉ាង

១.ការជឿកម្មៈ **កម្ម** ជាភាសាបាលី ប្រែថាអំពើដោយចេតនា ឬ ប្រែថាអ្វីដែលគេធ្វើដោយចេតនា ។ កម្មមាន ២ យ៉ាងគឺ កុសលកម្ម ប្រែថា អំពើល្អ និង អកុសលកម្ម ប្រែថា អំពើអាក្រក់ ។

កុសលកម្មបានដល់ ការឲ្យទាន ការរក្សាសីល ការចម្រើនភាវនា និងការធ្វើសេចក្តីល្អផ្សេងៗជាច្រើនទៀត ដែលជាហេតុនាំមកនូវសេចក្តីសុខ សេចក្តីចម្រើន ទាំងក្នុងលោកនេះ និងលោកខាងមុខ ។ អកុសលកម្មបានដល់ ការប្រព្រឹត្តអាក្រក់ដោយកាយ មានការសម្លាប់សត្វ ការលួចទ្រព្យរបស់អ្នកដទៃ និងការប្រព្រឹត្តខុសសីលធម៌ជាមួយប្រពន្ធ និងកូនអ្នកដទៃ ការប្រព្រឹត្តអាក្រក់ដោយវាចា មានការនិយាយកុហក និយាយញុះញង់ និយាយចាក់ដោតឬជេរប្រទេច និង

និយាយពាក្យឥតប្រយោជន៍ផ្សេងៗ និងការប្រព្រឹត្ត អាក្រក់ដោយចិត្ត មានការសម្លឹងរំពៃចង់បានទ្រព្យ របស់គេ ការគិតបៀតបៀនគេ និងការយល់ខុស ចាកការពិតជាដើម ដែលជាហេតុនាំមកនូវសេចក្ដីទុក្ខ ក្នុងលោកនេះ និង លោកខាងមុខ ។

ការជឿកម្ម គឺជាការជឿទៅលើអំពើល្អ និងអំពើ អាក្រក់ ដែលសត្វលោកតែងតែប្រព្រឹត្ត ជាប្រក្រតី ក្នុងជីវិតប្រចាំថ្ងៃ ហើយអំពើទាំងនោះនឹងនាំមកនូវផល ដល់អ្នកធ្វើវិញ ។ អំពើល្អតែងចែកសត្វឲ្យខ្ពង់ខ្ពស់ អំពើអាក្រក់តែងចែកសត្វឲ្យថោកទាប ។ ដូច្នេះទើបបាន ជាមនុស្សមានសភាពផ្សេងគ្នា ដោយទ្រព្យ ដោយជាតិ ត្រកូល ដោយពណ៌សម្បុរ ដោយគ្រឿងប្រើប្រាស់ ជាដើម ។ មានអ្នកខ្លះ មានបានសំបូរសប្បាយ

វហូតដល់បរិភោគប្រើប្រាស់មិនអស់ អ្នកខ្លះក្រដល់ថ្នាក់ដើរសុំទាន ។ ទាំងនេះ គឺជាសភាពពិតនៃជីវិត ។ អ្នកមានបានសំបូរសប្បាយ មកពីធ្លាប់ឲ្យទាន និងមិនធ្លាប់លួចរបស់អ្នកដទៃ ឯអ្នកខ្លះខាត កំសត់ទុគ៌ត មកពីមិនធ្លាប់ឲ្យទាន និងធ្លាប់លួចទ្រព្យរបស់គេជាដើម ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងថាៈ កុសលកម្មតែងនាំសត្វឲ្យបានសេចក្ដីសុខចម្រើន បានញ៉ាំងសត្វឲ្យកើតក្នុងសុគតិសួគ៌ នាំឲ្យសត្វបានលុះមគ្គផលជាលោកុត្តរថែមទៀត ។ អកុសលកម្ម រមែងញ៉ាំងសត្វឲ្យដល់នូវសេចក្ដីវិនាសទុក្ខលំបាក មានការញ៉ាំងសត្វឲ្យកើតក្នុងអបាយភូមិមាននរកជាដើម ។

២.ការជឿផលរបស់កម្មៈ ផលរបស់កម្មមានពីរយ៉ាងគឺ ផលរបស់កុសលកម្ម និងផលរបស់

អកុសលកម្ម ។ ផលរបស់កុសលកម្ម គឺជាសេចក្ដីសុខ សេចក្ដីចម្រើន និងការមានរបស់ប្រើប្រាស់គ្រប់គ្រាន់ តាមសេចក្ដីប្រាថ្នាត្រូវការរបស់ខ្លួន ពោលគឺការបាន នូវឥដ្ឋារម្មណ៍ (អារម្មណ៍ជាទីពេញចិត្ត) ។ ផលរបស់ អកុសលកម្ម គឺជាសេចក្ដីទុក្ខ សេចក្ដីវិនាស ការមិន មានរបស់ប្រើប្រាស់គ្រប់គ្រាន់ តាមសេចក្ដីប្រាថ្នា ត្រូវការរបស់ខ្លួន ពោលគឺការបាននូវអនិដ្ឋារម្មណ៍ (អារម្មណ៍មិនជាទីពេញចិត្ត) ។

ការជឿផល គឺជាការជឿទៅតាមសេចក្ដីពិតថា: សត្វលោកទទួលបានសេចក្ដីសុខ សេចក្ដីទុក្ខក្នុងជីវិត ប្រចាំថ្ងៃ គឺជាការទទួលផលនៃអំពើដែលខ្លួនបានធ្វើ ហើយក្នុងកាលមុន ។ អ្វីៗទាំងពួងក្នុងលោកនេះ កើតមកអំពីហេតុ ដូច្នេះជីវិត និងអ្វីៗដែលយើងមាន

និងជួបប្រទះក្នុងជីវិតរាល់ថ្ងៃនេះ គឺសុទ្ធតែជាផលនៃហេតុ គឺអំពើដែលយើងបានធ្វើហើយទាំងអស់ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា: សត្វទាំងឡាយកំពុងបានសេចក្តីសុខ និងសេចក្តីចម្រើន មានការសោយសេចក្តីសុខ ក្នុងមនុស្សសម្បត្តិ ឬសគ្គសម្បត្តិ (សម្បត្តិរបស់ទេវតា) ឬក៏កំពុងចម្រើនដោយ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ ក្នុងឋាននៃមនុស្សជាដើម មកអំពីកម្មជាកុសលជាហេតុបច្ច័យ ។ សត្វទាំងឡាយកំពុងដល់នូវសេចក្តីទុក្ខ និងសេចក្តីវិនាសធំ មានសត្វដែលកំពុងសោយទុក្ខក្នុងមហានរកជាដើម ឬសត្វទាំងឡាយដែលកើតក្នុងឋានមនុស្ស កំពុងដល់នូវសេចក្តីវិនាស មានការវិនាសបាត់បង់ទ្រព្យសម្បត្តិ មានអាយុខ្លី មានជំងឺច្រើន

ជាដើម មកតែអំពីកម្មជាអកុសលជាហេតុបច្ច័យ ។

៣.ការជឿថា សត្វទាំងឡាយមានកម្មដែលខ្លួនធ្វើហើយជារបស់ខ្លួន: ទ្រព្យសម្បត្តិក្នុងលោក មានមាសប្រាក់ជាដើម ដែលសត្វលោកសម្គាល់ថាជារបស់ខ្លួន អាចវិនាសដោយភ្លើង ទឹក ចោរលួច ចោរប្លន់ជាដើម ហើយមិនអាចជាប់តាមខ្លួនក្រោយអំពីសេចក្ដីស្លាប់បានទេ ។ ទ្រព្យសម្បត្តិតែម្យ៉ាងដែលជាប់តាមខ្លួន គឺអំពើដែលសត្វធ្វើហើយ ។ មានតែអំពើតាមផ្លូវកាយ វាចា និងចិត្តរបស់សត្វទាំងឡាយប៉ុណ្ណោះ តែងជាប់តាមខ្លួនក្នុងជាតិនេះ និងជាតិខាងមុខ ។ អំពើទាំងនោះមិនអាចវិនាសដោយភ្លើង ទឹក ចោរលួច ចោរប្លន់ជាដើមឡើយ ។ ព្រោះហេតុនោះ ពាក្យថា សត្វទាំងឡាយមានកម្មដែលខ្លួនធ្វើហើយជារបស់ខ្លួន គឺដោយសារអំពើដែលខ្លួនធ្វើហើយតែងជាប់តាមខ្លួនគ្រប់ទីកន្លែង ទាំង

ក្នុងជាតិនេះ និងជាតិខាងមុខ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា: សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរឭកសត្វលោកធ្វើកម្មយ៉ាងណា ទោះល្អក្តី អាក្រក់ក្តី សត្វទាំងឡាយនឹងជាអ្នកទទួលមត៌កនៃកម្មទាំងនោះ ។

៤.ការជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគត: គឺការជឿថា ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ដែលបានត្រាស់ដឹងឡើង និងនឹងត្រាស់ដឹងក្នុងកាលជាខាងមុខ សុទ្ធតែត្រូវបំពេញពុទ្ធការកធម៌គឺ ការឲ្យទាន ការរក្សាសីល ការចេញបួស ការសន្សំបញ្ញា សេចក្តីព្យាយាម សេចក្តីអត់ធន់ សេចក្តីពិតទៀងត្រង់ ការតាំងចិត្តមាំ ការរាប់អាន និងការតម្កល់ចិត្តជាកណ្តាលចំពោះសព្វសត្វទូទៅ ។ម្យ៉ាងទៀតគឺការ

ជឿចំពោះព្រះពុទ្ធគុណទាំង ១០ មានការជឿថា: ព្រះអង្គជាអ្នកឆ្ងាយចាកកិលេស ជាអ្នកត្រាស់ដឹងដោយប្រពៃ ជាអ្នកបរិបូណ៌ដោយវិជ្ជានិងចរណៈ ជាអ្នកយាងទៅដោយល្អ ជាអ្នកជ្រាបច្បាស់នូវអ្វីៗទាំងអស់ក្នុងលោក ជាអ្នកប្រសើរដោយគុណមានសីលជាដើម ជាអ្នកទូន្មានបុរសស្ត្រីដែលគួរទូន្មានបាន ជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ជាអ្នកត្រាស់ដឹងនូវសេចក្តីពិតដ៏ប្រសើរបំផុតទាំង ៤ និងការជឿថា ទ្រង់មិនត្រឡប់មកកើតក្នុងលោកនេះទៀតឡើយ ។ ប្រការមួយទៀតគឺការជឿចំពោះធម៌ ដែលទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ មានចារឹកទុកក្នុងព្រះត្រៃបិដក អដ្ឋកថា និងក្នុងគម្ពីរដីកានានាជាច្រើនទៀត ។ ធម៌ទាំងនោះគឺជាមាគ៌ាដ៏ល្អ សម្រាប់ដឹកនាំជីវិតឆ្ពោះទៅរកសេចក្តីសុខចម្រើន និងទៅរកទីដែលគ្មានទុក្ខបៀតបៀន ។

២. ឧបាសកជាអ្នកមានសីល

ពាក្យថា **សីល** ជាភាសាបាលី ដែលមានអត្ថន័យថា ប្រក្រតី ដោយអំណាចនៃកិរិយាតម្កល់ទុកដោយប្រពៃ គឺភាពមិនរាត់រាយនៃកាយកម្ម វចីកម្ម និងមនោកម្ម និងដោយអំណាច នៃកិរិយាចូលទៅទ្រទ្រង់ គឺការតម្កល់ទុកនូវកុសលធម៌ទាំងឡាយមិនឲ្យសាបសូន្យ ។

សីលមានលក្ខណាទិចតុក្កៈដូច្នេះ

១. សីលនលក្ខណំ: មានសភាពប្រក្រតី ជាលក្ខណៈ ។

២. ទុស្សីល្យវិទ្ធំសនរសំ: មានការកំចាត់បង់នូវភាពទ្រុស្តសីល ជាកិច្ច ។

៣. **សោចេយ្យប្បច្ចុប្បដ្ឋានំ:** មានភាពស្អាត ជាអាការប្រាកដ ។

៤. **ហិរោត្តប្បបទដ្ឋានំ:** មានសេចក្ដីខ្មាសបាប និងសេចក្ដីខ្លាចបាប ជាហេតុជិត ។

ក្នុងនាមជាពុទ្ធបរិស័ទ យើងត្រូវតែជាអ្នកមានសីល ។ ឯសីលសម្រាប់ពុទ្ធបរិស័ទជាគ្រហស្ថនោះ គឺមាននិច្ចសីល (សីល ៥) ឧបោសថសីល (សីល ៨) និងអតិរេកសីល (សីល ១០) ។

សីល ៥ នោះគឺ ការវៀរចាកការសម្លាប់សត្វមានជីវិត ១ ការវៀរចាកការលួចទ្រព្យរបស់អ្នកដទៃ ១ ការវៀរចាកការប្រព្រឹត្តខុសសីលធម៌ ជាមួយនឹងប្រពន្ធ និងកូនអ្នកដទៃ ១ ការវៀរចាកការនិយាយកុហក ១ និងការវៀរចាកការផឹកគ្រឿងស្រវឹង និងការប្រើប្រាស់

គ្រឿងញៀន ១ ។ សីល ៨ នោះគឺ ការវៀរចាកការសម្លាប់សត្វមានជីវិត ១ ការវៀរចាកការលួចទ្រព្យរបស់អ្នកដទៃ ១ ការវៀរចាកការសេពមេថុន (ការរួមសង្វាស) ១ ការវៀរចាកការនិយាយពាក្យកុហក ១ ការវៀរចាកការផឹកគ្រឿងស្រវឹង និងការប្រើប្រាស់គ្រឿងញៀន ១ ការវៀរចាកការបរិភោគអាហារក្រោយពេលថ្ងៃត្រង់ ១ ការវៀរចាកការរាំច្រៀងប្រគំនិងមើលសិល្បៈ និងការតាក់តែងកាយដោយគ្រឿងតុបតែងផ្សេងៗ ១ និងការវៀរចាកការដេក ឬអង្គុយលើទីដេកទីអង្គុយខ្ពស់ពេក និងល្អប្រសើរពេក ១ ។ សីល ១០ នោះគឺ ការវៀរចាកការសម្លាប់សត្វមានជីវិត ១ ការវៀរចាកការលួចទ្រព្យរបស់អ្នកដទៃ ១ ការវៀរចាកការសេពមេថុន ១ ការវៀរចាកការនិយាយពាក្យកុហក ១ ការវៀរចាកការផឹកគ្រឿងស្រវឹង និង

ការប្រើប្រាស់គ្រឿងញៀន ១ ការវៀរចាកការបរិភោគអាហារក្រោយពេលថ្ងៃត្រង់ ១ ការវៀរចាកការរាំច្រៀងប្រគំនិងមើលសិល្បៈ ១ ការវៀរចាកការតាក់តែងកាយដោយគ្រឿងតុបតែងផ្សេងៗ ១ ការវៀរចាកការដេកឬអង្គុយលើទីដេកទីអង្គុយខ្ពស់ពេក និងល្អប្រសើរពេក ១ និងការវៀរចាកការកាន់មាសប្រាក់លុយកាក់របស់ខ្លួនដោយខ្លួនឯង ១ ។

កាលបើពុទ្ធបរិស័ទ មានសីលបរិបូណ៌ហើយ រមែងបានជួបប្រទះ នូវសេចក្តីចម្រើនរុងរឿងក្នុងជីវិតទាំងក្នុងលោកនេះ និងលោកខាងមុខ និងបានសម្រេចលោកុត្តរធម៌ជាទីបំផុតថែមទៀតផង ។ សមដូចព្រះពុទ្ធដីកាថាៈ សត្វទាំងឡាយបានទៅកាន់សុគតិ ក៏ព្រោះសីល បានបរិបូណ៌ដោយរបស់ប្រើប្រាស់ ក៏ព្រោះសីល បានដល់ទីរលត់ទុក្ខ (ព្រះនិព្វាន) ក៏ព្រោះសីល ព្រោះ

ហេតុនោះ សត្វទាំងឡាយគប្បីជម្រះសីលរបស់ខ្លួនឲ្យបានបរិសុទ្ធ ។ ម្យ៉ាងវិញទៀត សីលមានអានិសង្សច្រើនយ៉ាងផ្សេងពីនេះទៅទៀត ដូចដែលព្រះសីលវត្ថេរសម្ដែងទុកក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថាថា:

សីលមេវិធ សិក្ខេថ អស្មឹ លោកេ សុសិក្ខិតំ

សីលំ ហិ សព្វសម្បត្តឹ ឧបនាមេតិ សេវិតំ ។

បុគ្គលគប្បីសិក្សានូវសីល ឲ្យជាសីលដែលខ្លួនសិក្សាល្អហើយក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេពហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។

សីលំ រក្ខេយ្យ មេធាវី បត្ថយានោ តយោ សុខេ

បសំសំ វិត្តិលាភញ្ច បេច្ច សគ្គេ បមោទនំ ។

ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ៣ យ៉ាងគឺ សេចក្តីសរសើរ ១ ការបាននូវសេចក្តីត្រេកអរ ១ ការលះលោកនេះទៅហើយ រីករាយក្នុងស្ថានសួគ៌ ១ គប្បីរក្សានូវសីល ។

សីលវា ហិ ពហូ មិត្តេ សញ្ញមេនាធិគច្ឆតិ

ទុស្សីលោ បន មិត្តេហិ ធំសតេ បាបមាចរំ ។

ពិតណាស់ បុគ្គលអ្នកមានសីល រមែងបាននូវមិត្តទាំងឡាយច្រើន ដោយការសង្រួម ចំណែកបុគ្គលទ្រុស្តសីល កាលប្រព្រឹត្តអាក្រក់ រមែងឃ្លាតចាកមិត្តទាំងឡាយ ។

អវណ្ណញ្ច អកិត្តិញ្ច ទុស្សីលោ លភតេ នរោ

វណ្ណំ កិត្តី បសំសញ្ច សទា លភតិ សីលវា ។

ជនទ្រុស្តសីល រមែងបាននូវទោសផង នូវដំណិះដំណៀលផង ឯជនអ្នកមានសីល រមែងបាននូវគុណផង នូវកិត្តិសព្ទផង នូវសេចក្តីសរសើរផង សព្វៗកាល ។

អាទិ សីលំ បតិដ្ឋា ច　　កល្យាណានញ្ច មាតុកំ

បមុខំ សព្វធម្មានំ　　តស្មា សីលំ វិសោធយេ ។

សីលជាខាងដើម ជាទីតាំង ជាមេនៃកល្យាណធម៌ និងជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះ បុគ្គលគប្បីជម្រះនូវសីល ។

វេលា ច សំវរំ សីលំ　　ចិត្តស្ស អភិហាសនំ

តិត្ថញ្ច សព្វពុទ្ធានំ　　តស្មា សីលំ វិសោធយេ ។

សីលជាប្រាំង ជាទំនប់ ជាគ្រឿងញ៉ាំងចិត្តឲ្យរីករាយ

ទាំងជាកំពង់ របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ព្រោះហេតុនោះ បុគ្គលគប្បីជម្រះនូវសីល ។

សីលំ ពលំ អប្បដិមំ សីលំ អាវុធមុត្តមំ

សីលំ អាភរណំ សេដ្ឋំ សីលំ កវចមព្ភុតំ ។

សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន សីលជាអាវុធដ៏ឧត្តម សីលជាគ្រឿងអាភរណៈដ៏ប្រសើរ សីលជាគ្រឿងក្រោះដ៏អស្ចារ្យ ។

សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ

សីលំ វិលេបនំ សេដ្ឋំ យេន វាតិ ទិសោ ទិសំ ។

សីលជាស្ពានមានសក្តិធំ សីលជាគ្រឿងក្រអូបដ៏ប្រសើរ សីលជាគ្រឿងលាបដ៏ប្រសើរ តែងបក់ទៅសព្វៗទិស ។

សីលំ សម្ពលមេវគ្គំ សីលំ បាថេយ្យមុត្តមំ

សីលំ សេដ្ឋោ អតិវាហោ យេន វាតិ ទិសោ ទិសំ ។

សីលជាកញ្ចប់បាយដ៏ប្រសើរ សីលជាស្បៀងដ៏ឧត្តម សីលជាវាហនៈដ៏ប្រសើរ សម្រាប់ទៅកាន់ទិសទាំងពួង ។

ឥធេវ និន្ទំ លភតិ បេច្ចាបាយេ ច ទុម្មនោ

សព្វត្ថ ទុម្មនោ ពាលោ សីលេសុ អសមាហិតោ ។

បុគ្គលពាលមានចិត្តអាក្រក់ក្នុងទីទាំងពួង មិនតាំងមាំក្នុងសីលទាំងឡាយ រមែងបានទូវសេចក្តីនិន្ទាក្នុងលោកនេះផង លុះលះលោកនេះទៅហើយ រមែងមានចិត្តជាទុក្ខក្នុងអបាយផង ។

ឥធេវ កិត្តឹ លភតិ   បេច្ច សគ្គេ ច សុមនោ
សព្វត្ថ សុមនោ ធីរោ   សីលេសុ សុសមាហិតោ ។

អ្នកប្រាជ្ញមានចិត្តល្អក្នុងទីទាំងពួង តាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវកិត្តិសព្ទក្នុងលោកនេះផង លុះលះលោកនេះទៅ រមែងមានសេចក្ដីរីករាយក្នុងស្ថានសួគ៌ផង ។

សីលមេវ ឥធ អគ្គំ   បញ្ញវា បន ឧត្តមោ
មនុស្សេសុ ច ទេវេសុ សីលបញ្ញាណតោ ជយំ ។

សីលជាកំពូលក្នុងលោកនេះ ចំណែកបុគ្គលមានប្រាជ្ញាក៏ឧត្តមដែរ ជ័យជម្នះក្នុងលោកនិងទេវលោក ព្រោះសីលនិងបញ្ញា ។

៣.ឧបាសកជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល

នៅក្នុងគម្ពីរមង្គលត្ថទីបនី មានសម្ដែងរឿងរ៉ាវចលាចល ដែលកើតឡើងដោយសារតែមនុស្សនាំគ្នាស្វែងរកមង្គល ហើយភ្ញាក់ផ្អើលកូកក្ដឹកទៅជឿតាមបុរស ៣ នាក់ ដែលពោលអះអាងថា ការឃើញរូបជាមង្គល ការឮសម្លេងជាមង្គល ការធុំក្លិន លិទ្ធភ្លក្សរស ប៉ះពាល់វត្ថុផ្សេងៗ ដោយកាយជាមង្គល ។ មានអ្នកខ្លះប្រកាន់តាមអ្នកទី ១ ថា ការឃើញរូបជាមង្គល អ្នកខ្លះប្រកាន់តាមអ្នកទី ២ ថា ការឮសម្លេងជាមង្គល អ្នកខ្លះប្រកាន់តាមអ្នកទី ៣ ថា ការធុំក្លិន លិទ្ធភ្លក្សរស ប៉ះពាល់វត្ថុផ្សេងៗ ដោយកាយជាមង្គល ។ ការប្រកាន់តែរៀងៗខ្លួន ជាហេតុឲ្យកើតមានកោលាហល មិនត្រឹមតែក្នុងមនុស្សលោកនេះទេ គឺរហូតដល់ទៅស្ថានទេវតា មារព្រហ្មទៀតផង ។ កោលាហលនេះបន្តអស់រយៈពេល

ដល់ទៅ ១២ ឆ្នាំ ។ ពេលដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងនូវមង្គល ៣៨ ប្រការក្នុងមង្គលសូត្រ ទើបកោលាហលនេះ ស្ងប់រម្ងាប់ ។ មង្គលភ្ញាក់ផ្អើល ដែលបង្កកោលាហលនៅក្នុងលោកនេះ មិនមែនមាន ត្រឹមតែ ៣ ដូចខាងលើនេះទេ គឺនៅមានច្រើនលើស ពីនេះទៅទៀត ។ មង្គលភ្ញាក់ផ្អើលទាំងអស់តែងកើត ឡើង ដោយសារមនុស្សមានគំនិតទន់ខ្សោយ ខ្វះការ ចេះដឹង និងខ្វះការពិចារណា ចេះតែទទួលយកការបក ស្រាយបំភិតបំភ័យ ពីសំណាក់ពួកមនុស្សអាត្មានិយម មួយចំនួន ដែលប្រាថ្នាតែប្រយោជន៍ផ្ទាល់ខ្លួន ហើយ បង្កើតជាពិធីកម្មផ្សេងៗ ថាជាការធ្វើដើម្បីបានមង្គល សេរីសួស្តី សម្រាប់បោកបញ្ឆោតគេយកប្រាក់ និង សម្ភារៈសម្រាប់ប្រើប្រាស់ខ្លួនឯង ។

ក្នុងនាមជាពុទ្ធបរិស័ទ យើងមិនត្រូវកាន់យកអ្វីមួយ

ដោយមិនបានពិចារណាហេតុផលនោះឡើយ ។ ព្រះពុទ្ធសាសនា គឺជាសាសនាហេតុផល ព្រោះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ធម៌ទាំងឡាយកើតអំពីហេតុ ។ ជាឧទាហរណ៍ នៅក្នុងមង្គលសូត្រ មង្គលទី ១ កិរិយាមិនសេពគប់បុគ្គលពាលជាមង្គលដ៏ឧត្តម ដោយសេចក្តីថា បើជនណាសេពគប់បុគ្គលពាល ជននោះនឹងត្រូវបុគ្គលពាលដឹកនាំឲ្យធ្វើអាក្រក់ មានការលួចប្លន់ជាដើម ហើយត្រូវទទួលរងទុក្ខទោស មានការជាប់គុកប្រវាក់ខ្នោះឃ្នាង ឬត្រូវគេចាប់បាន ហើយវាយដំប្រំធាក់រហូតដល់ស្លាប់ ឬស្ទើរនឹងស្លាប់ជាដើម ។ ផ្ទុយទៅវិញ បើមិនសេពគប់បុគ្គលពាលទេ នឹងមិនជួបប្រទះទុក្ខទោសទាំងអម្បាលនោះឡើយ ។ នេះជាហេតុផលនៃការមិនសេពគប់បុគ្គលពាល ទើបទ្រង់ត្រាស់សម្តែងថា អំពើបែបនេះជាមង្គល ។ មង្គលទី ២ ទ្រង់ត្រាស់ថា

កិរិយាសេពគប់បណ្ឌិតជាមង្គលដ៏ឧត្តម សេចក្តីថា កាលបើជនណាសេពគប់បណ្ឌិត ជននោះនឹងត្រូវបណ្ឌិតដឹកនាំឲ្យធ្វើល្អ ឲ្យប្រឹងប្រែងសិក្សាជាដើម រមែងបានកប់ប្រសព្វនឹងលាភសំណាងផ្សេងៗជាច្រើន ។ នេះជាហេតុផលនៃការសេពគប់បណ្ឌិត ។ មិនមែនមានតែមង្គលពីរនេះទេ ដែលប្រកបដោយហេតុផល សូម្បីមង្គលទាំងអស់ក្នុងមង្គលសូត្រ ក៏សុទ្ធតែប្រកបដោយហេតុផល ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាៈ មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលភ័យគ្របសង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាម និងដើមឈើដែលជាចេតិយទាំងឡាយខ្លះ ជាទីពឹង ។ ទីពឹងនុ៎ះឯងមិនមែនជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះមិនមែនជាទីពឹងដ៏ឧត្តម បុគ្គលមិនដែលរួចស្រឡះចាក

ទុក្ខទាំងពួង ព្រោះអាស្រ័យទីពឹងនុ៎ះទេ ។ បុគ្គលណាមួយបានដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទីរឭក ហើយឃើញនូវអរិយសច្ចៈទាំង ៤ គឺ សេចក្តីទុក្ខ ១ សមុទយៈជាដែនកើតឡើងព្រមនៃសេចក្តីទុក្ខ ១ និរោធជាទីកន្លងបង់នូវសេចក្តីទុក្ខ ១ មគ្គមានអង្គ ៨ ដ៏ប្រសើរដែលញុំាងសត្វឲ្យដល់ព្រះនិព្វាន ជាស្ថានស្ងប់រម្ងាប់បង់នូវសេចក្តីទុក្ខ ១ ដោយប្រាជ្ញាដ៏ត្រូវ ។ ទីពឹងនុ៎ះឯងជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះជាទីពឹងដ៏ឧត្តម បុគ្គលរមែងរួចចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។

ព្រះពុទ្ធវចនៈខាងលើនេះ គឺជាគ្រឿងឆ្លុះបញ្ចាំងឲ្យឃើញពីភាពទន់ខ្សោយពិតប្រាកដរបស់មនុស្សយើង ។ មនុស្សយើង កាលណាមានទុក្ខទោសវិបត្តិកយន្តរាយកើតឡើងហើយ រមែងត្រូវការជំនួយ ត្រូវការទីពឹង

ហើយការខ្វះខាតចំណេះដឹង និងការមិនបានពិចារណាហេតុផល ជាកត្តាដែលនាំឲ្យមនុស្សទៅស្វែងរកជំនួយស្វែងរកទីពឹង ដែលមិនពិត និងមិនមានសារៈខ្លឹមសារនាំឲ្យតែខាតបង់ពេលវេលា ប្រាក់កាស និងទ្រព្យសម្បត្តិផ្សេងៗឥតអំពើ ។ ជួនកាលការស្វែងរកបែបនេះ អាចនាំឲ្យមានគ្រោះថ្នាក់ផ្សេងៗច្រើនយ៉ាងទៀតផង ឬក៏នាំឲ្យមានគ្រោះថ្នាក់ធំដុំរហូតដល់បាត់បង់ជីវិតក៏សឹងមាន ។

ការប្រកាន់មង្គលភ្ញាក់ផ្អើលផ្សេងៗ មានការបួងសួង អង្វរករសុំសេចក្តីសុខ សេចក្តីចម្រើនអំពីអ្នកនេះ អំពីអ្នកនោះ ដែលគេយល់ថាពូកែ យល់ថាជាព្រះអំពីវត្ថុនេះ អំពីវត្ថុនោះ ដែលគេយល់ថាស័ក្តិសិទ្ធ យល់ថាមានឫទ្ធិអំណាច អាចញ៉ាំងសេចក្តីប្រាថ្នាឲ្យសម្រេចបាន និងអាចឲ្យបានសេចក្តីសុខសេចក្តីចម្រើនឲ្យបានទ្រព្យសម្បត្តិជាដើម មិនមែនជាទង្វើដែល

ពុទ្ធបរិស័ទត្រូវធ្វើទេ ព្រោះនៅក្នុងព្រះពុទ្ធសាសនា មិនមានអ្នកខ្វាំងពូកែ មិនមានព្រះ មិនមានវត្ថុស័ក្តិសិទ្ធណាមួយដែលអាចញ៉ាំងសេចក្តីប្រាថ្នា របស់អ្នកណាម្នាក់ឲ្យសម្រេចបានឡើយ ។ ព្រះសម្មាសម្ពុទ្ធមិនមែនជាព្រះដែលពូកែ អាចញ៉ាំងសេចក្តីប្រាថ្នារបស់មនុស្សឲ្យសម្រេចបានទេ ពុទ្ធបដិមាក្តី ទីសក្ការបូជាផ្សេងៗក្តី ក៏មិនមែនជាវត្ថុស័ក្តិសិទ្ធ ដែលអាចញ៉ាំងសេចក្តីប្រាថ្នារបស់មនុស្សឲ្យសម្រេចបានដែរ ព្រះអង្គគ្រាន់តែជាអ្នកដឹងនូវហេតុ ដែលនាំឲ្យបានសម្រេចសេចក្តីប្រាថ្នា ហើយប្រាប់ហេតុនោះដល់មនុស្សតែប៉ុណ្ណោះ ចំណែកឯពុទ្ធបដិមា និងទីសក្ការបូជាផ្សេងៗ ក៏គ្រាន់តែជាវត្ថុសម្រាប់ឲ្យយើងឃើញ ហើយញ៉ាំងចិត្តយើងឲ្យជ្រះថ្លារីករាយ ដើម្បីធ្វើការបូជា មានការថ្វាយបង្គំ ឬការថ្វាយគ្រឿងសក្ការៈផ្សេងៗ ដែលជាហេតុនាំមក

នូវសេចក្តីសុខផ្លូវចិត្ត និងសម្រេចជាបុណ្យកុសលផ្សេងៗតែប៉ុណ្ណោះ ។

មិនមែនតែនៅក្នុងពុទ្ធសាសនាទេ ដែលមិនមានអ្នកខ្លាំងពូកែ និងវត្ថុស័ក្តិសិទ្ធនោះ សូម្បីនៅក្នុងលោកទាំងអស់ គឺមនុស្សលោក ទេវលោក មារលោក និងព្រហ្មលោក ក៏មិនមានដែរ ព្រោះសត្វទាំងអស់ ដែលរស់នៅក្នុងលោកទាំងនេះ សុទ្ធតែស្ថិតនៅក្នុងអំណាចនៃការចាស់គ្រាំគ្រា ជំងឺជម្ងាត់ផ្សេងៗ និងសេចក្តីស្លាប់ដូចគ្នាទាំងអស់ ឥតមានវៀរលែងបុគ្គលរូបណាមួយឡើយ ។

ការយកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងជាទីរឭក គឺគ្រាន់តែជាការពឹងឲ្យជួយចង្អុលបង្ហាញប្រាប់ផ្លូវត្រូវផ្លូវត្រង់ ដើម្បីប្រតិបត្តិឆ្ពោះទៅរកសេចក្តីសុខ

សេចក្ដីចម្រើនតែប៉ុណ្ណោះ មិនមែនជាការពឹងឲ្យជួយធ្វើសេចក្ដីសុខ សេចក្ដីចម្រើនឲ្យទេ ។ ព្រះពុទ្ធគ្រប់ព្រះអង្គកើតឡើងក្នុងលោក ដើម្បីសេចក្ដីសុខ សេចក្ដីចម្រើន និងដើម្បីជាប្រយោជន៍ដល់សត្វលោក តែសត្វលោក មិនមែនទទួលបានប្រយោជន៍អំពីព្រះអង្គ ដោយសារតែទ្រង់ប្រទានឲ្យនោះទេ គឺបានមកអំពីការប្រព្រឹត្តតាមពាក្យប្រៀនប្រដៅ របស់ព្រះអង្គតែម្យ៉ាងគត់ប៉ុណ្ណោះឯង ។

បុគ្គលណា ឲ្យសេចក្ដីសុខដល់អ្នកដទៃ បុគ្គលនោះ រមែងដល់នូវសេចក្ដីសុខ មិនមែនបុគ្គលណាបួងសួង អង្វរករសុំសេចក្ដីសុខ បុគ្គលនោះរមែងដល់នូវសេចក្ដីសុខនោះទេ ។

៤ ឧបាសកជាអ្នកជឿតែកម្មមិនជឿមង្គល

ពាក្យថា **កម្ម** ក្នុងទីនេះ សំដៅយកទ្រឹស្តីកម្មផល ឬទ្រឹស្តីហេតុផលរបស់ព្រះពុទ្ធសាសនា និងពាក្យថា មង្គល ក្នុងទីនេះសំដៅយកមង្គលភ្ញាក់ផ្អើល ដូចដែលបានរៀបរាប់មកហើយក្នុងខាងលើ ។

ក្នុងទ្រឹស្តីកម្មផល ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងប្រៀបធៀប កម្មនិងផល ទៅនឹងពូជរបស់រុក្ខជាតិដូច្នេះថា: **យាទិសំ វប្បតេ ពីជំ តាទិសំ លភតេ ផលំ កល្យាណការី កល្យាណំ បាបការី ច បាបកំ** ។ បុគ្គលសាបព្រោះពូជយ៉ាងណា រមែងទទួលបានផលយ៉ាងនោះ អ្នកមានប្រក្រតីធ្វើល្អ រមែងទទួលបានផលល្អ អ្នកមានប្រក្រតីធ្វើអាក្រក់ រមែងទទួលបានផលអាក្រក់ ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងឡើង នូវពុទ្ធវចនៈនេះ គឺដោយពុទ្ធបំណងចង់ឲ្យសត្វលោក ជឿទៅតាមសេចក្តីពិតនៃទំនៀមរបស់កម្ម ដែលតែងតែឲ្យផលទៅតាមទង្វើដែលសត្វលោកបានធ្វើហើយ ។ ពូជស្រូវទាំងឡាយ មានស្រូវដំណើបជាដើម ដែលគេព្រោះហើយទៅលើដីស្រែ កាលណាបើដល់គ្រប់រដូវកាលត្រូវឲ្យផលហើយ រមែងឲ្យផលជាស្រូវដំណើប ដូចពូជរបស់វាដែរ យ៉ាងណាមិញ កម្មល្អជាពូជ ដែលសត្វលោកសាបព្រោះ គឺធ្វើហើយ កាលបើដល់ពេលវេលាដែលវាត្រូវឲ្យផលហើយ រមែងឲ្យផលជាផលល្អដូចពូជវា កម្មអាក្រក់ជាពូជ ដែលសត្វលោកសាបព្រោះហើយ កាលបើដល់ពេលដែលវាត្រូវឲ្យផលហើយ រមែងឲ្យផលអាក្រក់ដូចពូជវា ក៏យ៉ាងនោះដែរ ។

ការសម្តែងប្រៀបធៀបទំនៀមរបស់កម្ម ទៅនឹងទំនៀមរបស់ពូជវុក្ខជាតិ គឺដើម្បីឲ្យពុទ្ធបរិស័ទយល់ដោយសេចក្តីប្រៀបទៅនឹងអ្វី ដែលមានជាក់ស្តែងនៅក្នុងលោក ។ កាលណាពុទ្ធបរិស័ទបានយល់ទៅតាមសេចក្តីពិតហើយ ពុទ្ធបរិស័ទនឹងជឿតាមដោយឥតមានសេចក្តីសង្ស័យឡើយ ។

គោលដៅនៃពុទ្ធសាសនា ក្នុងការផ្សព្វផ្សាយជំនឿ គឺការលើកយកហេតុផល មកពន្យល់ឲ្យមនុស្សយល់ មិនមែនឲ្យចេះតែជឿតាម ចេះតែព្រមធ្វើតាម ដោយពុំបានពិចារណារកហេតុផលនោះឡើយ ។

ជាបរិស័ទរបស់ព្រះពុទ្ធសាសនា យើងត្រូវតែជាអ្នកជូន់ក្នុងហេតុផល ។ មុននឹងជឿទៅលើអ្វីមួយ យើងត្រូវពិចារណា រកហេតុផលឲ្យច្បាស់លាស់សិន

សឹមជឿ មិនត្រូវចេះតែជឿទាំងងងឹតងងល់នោះទេ។

ជំនឿកម្មផល ឬជំនឿហេតុផលនេះ ជាគុណសម្បត្តិរបស់ពុទ្ធបរិស័ទល្អ ឯជំនឿលើមន្តលក្ខាក់ផ្តើលផ្សេងៗ ជាគុណវិបត្តិរបស់ពុទ្ធបរិស័ទទៅវិញទេ ។ ដើម្បីបានជាពុទ្ធបរិស័ទល្អ យើងត្រូវជឿលើកម្ម និងផលរបស់កម្ម ព្រោះការជឿកម្ម និងផលរបស់កម្ម គឺជាការស្តែងចេញនូវការចេះដឹងដ៏ពិតប្រាកដ និងត្រឹមត្រូវរបស់ពុទ្ធបរិស័ទ ។

៥ ឧបាសកជាអ្នកមិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យតែក្នុងពុទ្ធសាសនា

ពាក្យថាទក្ខិណេយ្យបុគ្គល មានន័យថា បុគ្គលដែលគួរដល់ទក្ខិណា គឺទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា ។

កាលណាពុទ្ធបរិស័ទបានយល់ដឹងច្បាស់ អំពីហេតុផលហើយ ថាការធ្វើយ៉ាងនេះរមែងជាហេតុនាំមកនូវសេចក្តីសុខ ការធ្វើយ៉ាងនេះរមែងជាហេតុនាំមកនូវសេចក្តីទុក្ខ ក៏នឹងប្រាថ្នាធ្វើហេតុនៃសេចក្តីសុខតែម្យ៉ាង ។ ឯហេតុនៃសេចក្តីសុខនោះ ក្នុងពុទ្ធសាសនា ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងថា **សុខោ បុញ្ញស្ស ឧច្ចយោ** កិរិយាសន្សំបុណ្យជាហេតុនៃសេចក្តីសុខ ។

ដើម្បីសន្សំបុណ្យបាន ពុទ្ធបរិស័ទត្រូវស្គាល់បុណ្យ

និងហេតុដែលនាំឲ្យកើតបុណ្យ ឲ្យបានច្បាស់លាស់ ទើបអាចញ៉ាំងបុណ្យនោះឲ្យសម្រេចបាន ។ ពាក្យថា **បុណ្យ** មានន័យថា គុណជាតិណាតែងធ្វើចិត្តឲ្យថ្លាស្អាត គុណជាតិនោះឈ្មោះថា **បុណ្យ** ។ មានសេចក្តីអធិប្បាយថា ចិត្តរបស់មនុស្សសត្វរមែងថ្លាស្អាត ដោយអំណាចនៃសេចក្តីល្អគ្រប់បែបយ៉ាង និងផ្ទុយទៅវិញវាក៏រមែងល្អក់ស្រអាប់ ដោយអំណាចនៃសេចក្តីអាក្រក់គ្រប់បែបយ៉ាងដែរ ។ នៅក្នុងជីវិតរបស់មនុស្សសត្វ ចិត្តជាមេដឹកនាំ ឬជាមេបញ្ជាការធំ កាលណាបើចិត្តថ្លាស្អាត តាំងនៅក្នុងសេចក្តីល្អហើយ រមែងបញ្ជាឲ្យធ្វើសេចក្តីល្អតាមផ្លូវកាយ និងផ្លូវវាចាបាន តែថាប្រសិនបើកាលណាចិត្តល្អក់ស្រអាប់ និងតាំងនៅក្នុងសេចក្តីអាក្រក់ហើយ រមែងបញ្ជាឲ្យធ្វើសេចក្តីអាក្រក់តាមផ្លូវកាយ និងផ្លូវវាចាជាក់ជាមិនខានឡើយ ។

បុណ្យ មានហេតុដែលនាំឲ្យកើតឡើង ១០យ៉ាងគឺ ការឲ្យទាន ១ ការរក្សាសីល ១ ការចម្រើនសេចក្តីល្អ ១ ការគោរព មានការសំពះថ្វាយបង្គំជាដើម ១ ការខ្នះខ្នែងជួយបម្រើក្នុងកិច្ចការជាកុសល ១ ការសម្តែង និងការបង្ហាត់បង្រៀនធម៌ ១ ការយកចិត្តទុកដាក់រៀន និងស្តាប់ធម៌ដោយគោរព ១ ការចែកចំណែកនៃសេចក្តីល្អ ដែលខ្លួនបានធ្វើហើយដល់អ្នកដទៃ ១ ការត្រេកអរតាមសេចក្តីល្អដែលអ្នកដទៃបានធ្វើហើយ ១ និងការធ្វើការយល់ដឹងរបស់ខ្លួនឲ្យបានត្រឹមត្រូវ ១ ។

កាលបើបានស្គាល់បុណ្យ និងហេតុដែលនាំឲ្យកើតបុណ្យហើយ ពុទ្ធបរិស័ទរមែងប្រាថ្នាធ្វើបុណ្យទាំងឡាយ ឲ្យសម្រេចដោយល្អ ។ បុណ្យដែលអាចសម្រេចដោយល្អបាន គឺដោយសារបុគ្គលធ្វើទៅតាម

ហេតុទាំងឡាយខាងលើនេះឯង ព្រោះនៅក្នុងលោកនេះពុំមានហេតុដទៃណា ដែលអាចញុំាងបុណ្យឲ្យសម្រេចឡើយ ។

ការធ្វើបុណ្យ តាមហេតុដែលនាំឲ្យកើតបុណ្យមានការឲ្យទានជាដើមនោះ ពុទ្ធបរិស័ទរមែងត្រូវការស្វែងរកទក្ខិណេយ្យបុគ្គល ដើម្បីធ្វើបុណ្យជាមួយ ។ ឯទក្ខិណេយ្យបុគ្គល ដែលសមគួរក្នុងការធ្វើបុណ្យជាមួយ ហើយដែលអាចញុំាងបុណ្យដែលបុគ្គលធ្វើហើយឲ្យសម្រេចបានផលច្រើននោះ ព្រះសម្ពុទ្ធទ្រង់បានត្រាស់សម្តែងទុកនៅក្នុងទក្ខិណាវិភង្គសូត្រថា ជា ***ព្រះសង្ឃព្រះពុទ្ធសាសនា*** *ដោយពុទ្ធវចនៈថា: តថាគតពោលថា សង្ឃគតាទក្ខិណាទាន (ទានដែលបុគ្គលជឿនូវកម្មនិងផលរបស់កម្ម ហើយថ្វាយដល់សង្ឃ) មាន*

អានិសង្ស រាប់មិនបានប្រមាណមិនអស់ តថាគតមិនដែលពោល នូវបាដិបុគ្គលិកទាន (ទានដែលគេឲ្យចំពោះបុគ្គល) ថាមានផលច្រើនជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយឡើយ ។

ព្រះសង្ឃព្រះពុទ្ធសាសនា ពោលដោយសង្ឃគុណមានពីរយ៉ាងគឺ សម្មតិសង្ឃ និងអរិយសង្ឃ ។ សម្មតិសង្ឃ បានដល់ភិក្ខុ ភិក្ខុនី សាមណេរ និងសាមណេរី ដែលជាបព្វជិត ។ អរិយសង្ឃ បានដល់ព្រះអរិយបុគ្គល ៨ ពួក មានបុគ្គលដែលបានសម្រេចនូវសោតាបត្តិមគ្គ ជាខាងដើម និងបុគ្គលដែលបានសម្រេចនូវ អរហត្តផលជាទីបំផុត ។ ប៉ុន្តែព្រះសង្ឃក្នុងពុទ្ធវចនៈខាងលើនេះ សំដៅយកតែសម្មតិសង្ឃទេ មិនបានសំដៅយកអរិយសង្ឃផងឡើយ ។

សង្ឃគតាទក្ខិណាទាន ព្រះសាស្តាទ្រង់ត្រាស់ថា មាន ៧ យ៉ាងគឺ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក គឺភិក្ខុ និងភិក្ខុនី មានព្រះពុទ្ធជាប្រធាន ១ កាលបើព្រះពុទ្ធបរិនិព្វានទៅហើយ បុគ្គលឲ្យទានចំពោះព្រះសង្ឃទាំងពីរចំណែក ១ ឲ្យទានចំពោះតែភិក្ខុសង្ឃ ១ ឲ្យទានចំពោះតែភិក្ខុនីសង្ឃ ១ បុគ្គលទៅនិមន្តអំពីសំណាក់សង្ឃថា សូមលោកទាំងឡាយចាត់ពួកភិក្ខុប៉ុណ្ណេះ ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃដើម្បីខ្ញុំ ហើយទើបឲ្យទាន ១ បុគ្គលទៅនិមន្តអំពីសំណាក់សង្ឃថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះអំពីសង្ឃដើម្បីខ្ញុំ ហើយទើបឲ្យទាន ១ បុគ្គលទៅនិមន្តអំពីសំណាក់សង្ឃថា សូមលោកទាំងឡាយចាត់ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃដើម្បីខ្ញុំ ហើយទើប

ឲ្យទាន ១ ។ ចំណែកឯបាដិបុគ្គលិកទាន ព្រះអង្គទ្រង់ត្រាស់សម្តែងថាមាន ១៤ យ៉ាងគឺ បុគ្គលឲ្យទានចំពោះព្រះសម្មាសម្ពុទ្ធ ១ ឲ្យទានចំពោះព្រះបច្ចេកពុទ្ធ ១ ឲ្យទានចំពោះព្រះអរហន្តសាវក របស់ព្រះតថាគត ១ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ១ ឲ្យទានចំពោះអនាគាមិបុគ្គល ១ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ ឲ្យទានចំពោះសកទាគាមិបុគ្គល ១ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ១ ឲ្យទានចំពោះសោតាបន្នបុគ្គល ១ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល (មានអ្នកដល់ត្រៃសរណគមន៍ អ្នករក្សាសីល ៥ សីល ៨ ជាដើម

និងបព្វជិតក្នុងព្រះពុទ្ធសាសនា) ១ ឲ្យទានចំពោះអ្នកបួសខាងក្រៅព្រះពុទ្ធសាសនា ដែលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ១ ឲ្យទានចំពោះបុថុជ្ជនមានសីល ១ ឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល ១ ឲ្យទានចំពោះសត្វតិរច្ឆាន ១ ។

ចំណែកផលនៃបាដិបុគ្គលិកទាន ដែលបុគ្គលត្រូវទទួលបាន គឺការឲ្យទានចំពោះសត្វតិរច្ឆាន មានផលគុណមួយរយ ការឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល មានផលគុណមួយពាន់ ការឲ្យទានចំពោះបុថុជ្ជនមានសីល មានផលគុណមួយសែន ការឲ្យទានចំពោះអ្នកបួសខាងក្រៅពុទ្ធសាសនា ដែលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ មានផលគុណមួយសែនកោដិ ការឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ

សោតាបត្តិផល មានផលគុណរាប់មិនបាន ប្រមាណមិនអស់ នឹងបាច់ពោលទៅថ្វីដល់បុគ្គលថ្នាក់លើៗទៀត មានសោតាបន្នបុគ្គលជាដើម ដែលសុទ្ធតែមានគុណធម៌ខ្ពស់ៗជាងគ្នានិងគ្នាជាលំដាប់នោះ ក៏គឺរឹងរិតតែមានផលច្រើនជាងគ្នានិងគ្នា តាមលំដាប់ថ្នាក់នៃគុណធម៌របស់លោក ជាប្រាកដពុំខានឡើយ ។

ការធ្វើបុណ្យទាំងឡាយ មានទានជាដើមចំពោះបុគ្គល មានព្រះសម្មាសម្ពុទ្ធ ជាដើមរមែងមានផលច្រើន មានអានិសង្សច្រើនក៏ពិតមែនហើយ តែព្រះពុទ្ធអង្គទ្រង់ត្រាស់សរសើរ ការធ្វើចំពោះសង្ឃថាជាទានមានផលច្រើនជាងនោះទៅទៀត ដោយហោចទៅសូម្បីតែការធ្វើចំពោះគោត្រភូសង្ឃ (សង្ឃមានតែឈ្មោះ គឺសម័យដែលជិតអស់អាយុនៃពុទ្ធសាសនា មានបុគ្គលខ្លះ

បានយកក្រណាត់ស្បង់ចង់នៅក មានប្រពន្ធកូនជម្ចាតែសម្គាល់ខ្លួនថាជាសង្ឃ) ក៏មានផលច្រើនដែរ ។

ការធ្វើទានចំពោះសង្ឃ ដែលហៅថា សង្ឃគតាទក្ខិណាទាននេះ គឺការធ្វើដោយសេចក្តីកោតក្រែង ដោយសេចក្តីជ្រះថ្លាក្នុងសង្ឃ មិនមែនដោយសេចក្តីកោតក្រែង និងដោយសេចក្តីជ្រះថ្លាក្នុងបុគ្គលទេ ។ សេចក្តីកោតក្រែងក្នុងសង្ឃ គឺគោរពនិងជ្រះថ្លាចំពោះព្រះសង្ឃដោយទូទៅ មិនរើសមុខថា ភិក្ខុអង្គនេះជាព្រះថេរៈ មានវស្សាច្រើន លោកអង្គនេះជាសាមណេរទើបនឹងបួសឡើយ ។ ដូចជានាសម័យបច្ចុប្បន្ននេះ មានបុគ្គលខ្លះចូលចិត្តធ្វើបុណ្យ តែជាមួយព្រះថេរៈធំៗ ដោយគំនិតថា ព្រះគុណម្ចាស់អង្គនេះ ជាព្រះមេគណ ព្រះអនុគណ ចៅអធិការ គ្រូសូត្រ ឬក៏ជាធម្មាចារ្យល្បីៗ

មានធម្មាចារ្យសម្ដែងធម៌តាមវិន័យជាដើម ។ ដើម្បីធ្វើខ្លួនឲ្យបានជាពុទ្ធបរិស័ទល្អ យើងត្រូវធ្វើសេចក្ដីគោរពកោតក្រែង ចំពោះព្រះសង្ឃដោយទូទៅ ដោយហោចទៅសូម្បីតែសាមណេរតូច ទើបនឹងបួសបានមួយថ្ងៃក្ដី ក៏ជាព្រះសង្ឃក្នុងសង្ឃរតនៈដែរ ។

ដោយព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវផលនៃបុណ្យ ដែលបុគ្គលធ្វើហើយក្នុងសង្ឃដូច្នេះហើយ ទើបទ្រង់ត្រាស់នូវពុទ្ធវចនៈខាងលើនេះ ។ ព្រោះហេតុដូច្នោះហើយ ប្រសិនបើបុគ្គលណាប្រាថ្នាបុណ្យដែលមានផលច្រើន មានអានិសង្សច្រើន គប្បីធ្វើបុណ្យចំពោះសង្ឃ មិនគប្បីធ្វើបុណ្យចំពោះបុគ្គលឡើយ ។

ពុទ្ធបរិស័ទ ដែលមិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពុទ្ធសាសនា ហើយធ្វើបុណ្យតែក្នុងពុទ្ធសាសនា

គឺធ្វើបុណ្យតែចំពោះសង្ឃ មិនធ្វើបុណ្យចំពោះបុគ្គលឡើយ ។ ការធ្វើបុណ្យចំពោះសង្ឃ គឺជាការសម្តែងនូវសេចក្តីគោរពយ៉ាងក្រៃលែង ចំពោះព្រះសាស្តា ។

រឿងរ៉ាវដែលជាហេតុនាំឲ្យព្រះអង្គសម្តែងទក្ខិណាវិភង្គសូត្រ ក៏មកអំពីព្រះមាតុច្ឆារបស់ព្រះអង្គ គឺព្រះនាងបជាបតិគោតមី មានសេចក្តីជ្រះថ្លាដ៏ក្រៃលែងចំពោះព្រះអង្គ ហើយបានធ្វើសំពត់មួយគូដោយព្រះអង្គឯងដើម្បីថ្វាយព្រះពុទ្ធអង្គ តែព្រះពុទ្ធទ្រង់ត្រាស់ថាឲ្យថ្វាយចំពោះសង្ឃវិញ ព្រោះកាលបើព្រះនាងបានថ្វាយចំពោះសង្ឃហើយ ព្រះពុទ្ធក៏ឈ្មោះថា ព្រះនាងបានបូជាហើយដែរ ។

ពុទ្ធវចនៈ ក្នុងទក្ខិណាវិភង្គសូត្រ ព្រះអង្គត្រាស់សម្តែង ដើម្បីឲ្យពុទ្ធបរិស័ទមានចិត្តជូនចំពោះសង្ឃ

ព្រោះសម័យកាលជាខាងក្រោយមក មានតែព្រះសង្ឃទេ ដែលជាអ្នកអភិរក្សពុទ្ធសាសនាឲ្យស្ថិតនៅបានយូរ ជាអ្នកដឹកនាំពុទ្ធបរិស័ទ និងជាអ្នកផ្សព្វផ្សាយសាសនាតទៅ ។ និងម្យ៉ាងវិញទៀត កាលបើពុទ្ធបរិស័ទបានបូជាចំពោះសង្ឃហើយ ចំពោះព្រះពុទ្ធអង្គ ក៏ឈ្មោះថាពុទ្ធបរិស័ទបានបូជាហើយដែរ ។

មាតិកាធម៌ទាំង ៥ យ៉ាងនេះ គឺជាគោលការណ៍សម្រាប់អភិវឌ្ឍ និងជាមាគ៌ាដឹកនាំជីវិតរបស់ពុទ្ធ-បរិស័ទទៅរកសេចក្តីសុខ សេចក្តីចម្រើនពិតប្រាកដ និងជាឧបដិបត្តិ ដើម្បីធ្វើខ្លួនឲ្យក្លាយទៅជាពុទ្ធបរិស័ទដ៏ពិតប្រាកដរបស់ពុទ្ធសាសនាទៀតផង ។ សូមពុទ្ធ-បរិស័ទអាន ហើយពិចារណាខ្លឹមសារនៃធម៌ទាំងឡាយនេះ ដោយសេចក្តីពេញចិត្តចុះ ដើម្បីបានជាប្រយោជន៍

ដល់ខ្លួនឯង និងដល់សាសនាដ៏បវរនៃយើងទាំងអស់គ្នាផង ។ សូមឲ្យពុទ្ធបរិស័ទគ្រប់គ្នា បានជាកូនល្អរបស់ព្រះសម្មាសម្ពុទ្ធ ជាកូនដែលស្តាប់ និងធ្វើតាមឱវាទរបស់ព្រះពុទ្ធបិតា បានយ៉ាងខ្ជាប់ខ្ជួន និងត្រឹមត្រូវជានិច្ចនិរន្តរ៍តរៀងទៅ និងបានជា**ពុទ្ធបរិស័ទខ្មែរ**ដែលល្អ ឲ្យសមនឹងឈ្មោះនៃប្រទេសខ្មែរយើង ជា **ព្រះរាជាណាចក្រអច្ឆរិយៈ** បានទទួលយកព្រះពុទ្ធសាសនាមកធ្វើ ជាសាសនារបស់ជាតិ តាំងពីយូរលង់ណាស់មកហើយនោះ ព្រមទាំងឲ្យពុទ្ធបរិស័ទទូទាំងសកលលោកទទួលស្គាល់ថា **ពុទ្ធបរិស័ទខ្មែរ** ជា **ពុទ្ធបរិស័ទពិត** ព្រោះពុទ្ធបរិស័ទខ្មែរបានយល់ដឹង និងបានប្រតិបត្តិយ៉ាង ត្រឹមត្រូវតាមពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ ។

តើពុទ្ធសាសនាសម្តែងយ៉ាងណា ចំពោះជំនឿខាងព្រលឹង ?

ដើម្បីឆ្លើយតបទៅនឹងសំនួរនេះ សូមពុទ្ធបរិស័ទសិក្សាស្វែងយល់អំពីសេចក្តីពិតនៃជីវិត ជាមុនសិនទើបអាចយល់ដឹងបាន ។ **ជីវិត** មានន័យថា ដំណើរនៃការរស់នៅ ហើយការរស់នៅរបស់មនុស្សសត្វជារៀងរាល់ថ្ងៃនេះ គឺរស់នៅជាមួយនឹងរូបរាងកាយមួយដែលមានទទឹងមួយហត្ថ បណ្តោយមួយព្យាម ។ នៅក្នុងរូបរាងកាយនេះ មានធម្មជាតិម្យ៉ាងដែលមិនអាចមើលឃើញដោយភ្នែកអាស្រ័យនៅ ។ ធម្មជាតិនោះត្រូវបានគេហៅថា **ចិត្ត** ឬ **វិញ្ញាណ** ។

ក្នុងព្រះពុទ្ធសាសនា ព្រះពុទ្ធទ្រង់ត្រាស់សម្តែងអំពីជីវិតនេះថា ជាដំណើរ ឬការប្រព្រឹត្តទៅនៃគំនរ ៥ យ៉ាង

ដែលហៅថា **បញ្ចក្ខន្ធ** ។ បញ្ចក្ខន្ធ មាន រូបក្ខន្ធ គំនរនៃរូប (ធម្មជាតដែលមិនដឹងអារម្មណ៍ មានការបែកធ្លាយជាធម្មតា) វេទនាខន្ធ គំនរនៃវេទនា (ធម្មជាតិសោយអារម្មណ៍) សញ្ញាខន្ធ គំនរនៃសញ្ញា (ធម្មជាតិចាំនូវអារម្មណ៍) សង្ខារក្ខន្ធ គំនរនៃសង្ខារ (សភាវៈតាក់តែងលោក) វិញ្ញាណក្ខន្ធ គំនរនៃវិញ្ញាណ (ធម្មជាតដឹងច្បាស់នូវ អារម្មណ៍) ។

បញ្ចក្ខន្ធជាសង្ខតធម៌ ជាសភាវៈដែលមានបច្ច័យប្រជុំតាក់តែង កើតឡើងមកអំពីគ្រឿងតាក់តែង ស្ថិតនៅក្នុងអំណាចនៃលក្ខណៈ ៣ គឺ មិនទៀង ជារបស់ប្រែប្រួលផ្លាស់ប្តូរជានិច្ច និងមិនស្ថិតនៅក្នុងអំណាចនៃបុគ្គលណាមួយឡើយ និងមានការកើតឡើងហើយបែកធ្លាយទៅវិញរៀងរាល់ខណៈ ។

ខន្ធទាំង ៥ នេះ យើងអាចហៅដោយសង្ខេបបាន ថា នាមរូប ។ នាមបានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ រូបបានដល់រូបក្ខន្ធ ។ នាមជាធម្មជាតិកើត និងរលត់ជាមួយគ្នាដោយមានវិញ្ញាណជាធំហៅថាចិត្ត និងខន្ធ ៣ ទៀតហៅថា ចេតសិក (ធម្មជាតិកើតនិងរលត់ជាដើមជាមួយចិត្ត) ។

ខន្ធប្បវត្តិ (ការប្រព្រឹត្តទៅនៃខន្ធ) ដែលហៅថាជីវិតនេះ មានការកើតឡើងនិងរលត់ទៅវិញ ជាតំណៗឥតមានរវាំងចន្លោះ ។ រូបជាបណ្តុំនៃធាតុ ដី ទឹក ភ្លើង ខ្យល់ ដែលតែងកើតឡើង ព្រោះមានគ្រឿងប្រជុំតាក់តែង ៤ យ៉ាងគឺៈ កម្ម ចិត្ត ឧតុ (រដូវ ឬអាកាសធាតុ) និង អាហារ ហើយតែងរលត់ទៅវិញនៅពេលដែលអស់អាយុ និងគ្រឿងតាក់តែងរបស់វា

និងត្រូវមានគ្រឿងតាក់តែងថ្មី មកតាក់តែងបង្កើតរូបថ្មី បន្តអំពីការរលត់ទៅនៃរូបចាស់ ។ ចិត្តក៏តែងកើតឡើង ព្រោះមានគ្រឿងប្រជុំតាក់តែង ហើយរលត់ទៅវិញ ព្រោះអស់អាយុ និងគ្រឿងប្រជុំតាក់តែង ហើយនិងត្រូវមានចិត្តថ្មី មកកើតបន្តទៀតដែរ ។ ទាំងអស់នេះ គឺជាសេចក្ដីពិតនៃជីវិត គឺជីវិតជាតំណនៃនាមរូប ដែលមានគ្រឿងប្រជុំ តាក់តែងតៗគ្នាយ៉ាងនេះឯង ។

តាមលទ្ធិព្រហ្មញ្ញ ដែលជាសាសនាបុរាណមួយរបស់ខ្មែរយើង បានសម្ដែងអំពីជីវិតនេះថា ជាសភាវៈម្យ៉ាងមានរូប ដែលកើតអំពីការផ្គុំឡើងនៃធាតុ ៤ យ៉ាង គឺ ដី ទឹក ភ្លើង ខ្យល់ និងសភាវៈម្យ៉ាងទៀតនៅខាងក្នុង ដែលមិនអាចមើលឃើញដោយភ្នែក ហៅថា **អាត្មន់** មានន័យថា **ព្រលឹង** ។ អាត្មន់ ជាសភាវៈម្យ៉ាងដែល

មិនចេះស្លាប់ បែកចេញមកអំពីព្រហ្ម័ន (សភាវៈដែលជាប្រភពនៃសភាវៈទូទៅទាំងអស់) ហើយត្រូវវិលវល់ត្រាច់រង្គាត់នៅក្នុងលោក ដោយអំណាចនៃកម្លាំងរុញច្រានម្យ៉ាង ឈ្មោះថា **កម្មិន** (អំពើ) និងនៅទីបំផុត នឹងត្រាច់រង្គាត់ទៅជួបជុំ នៅជាមួយព្រហ្ម័នវិញ ហើយនៅជាសុខក្សេមក្សាន្តតរៀងទៅ ។

ការស្លាប់ និងការកើត

ព្រះពុទ្ធសាសនាសម្តែងថាៈ សេចក្តីស្លាប់ ជាទីបំផុតនៃជីវិតក្នុងមួយអត្តភាព ។ ក្នុងខណៈនៃសេចក្តីស្លាប់ ចិត្តមួយដួង ជាចិត្តចុងក្រោយបំផុតក្នុងមួយជាតិធ្វើ **ចុតិកិច្ច** (កិច្ចឃ្លាតចាកភព) ហើយត្រូវមានចិត្តមួយដួងទៀត ជាចិត្តដំបូងបង្អស់ក្នុងកំណើតថ្មី មកធ្វើកិច្ចបន្តដោយឥតមានរវាំងចន្លោះ ហៅថា **បដិសន្ធិកិច្ច**

(កិច្ចតដោយចំពោះ) ។ សត្វលោកស្លាប់ និងកើតយ៉ាង នេះឯង គឺការកើត និងការស្លាប់ជាតំណនៃចិត្ត ។ ចំពោះអំពើ ដែលសត្វទាំងឡាយធ្វើហើយ រមែងឲ្យផលនៅក្នុងអត្តភាព ដែលកើតបន្តជានិច្ច ព្រោះចិត្តបានសន្សំយកនូវអំពើល្អ និងអាក្រក់ទាំងអស់ដែលបានធ្វើហើយ និងនឹងត្រូវបញ្ជូនមកកាន់កពថ្មីដោយចុតិចិត្ត ព្រោះចុតិចិត្តជាទីអាស្រ័យដ៏មានកម្លាំង និងមិនមានរវាំងចន្លោះរបស់បដិសន្ធិចិត្ត ។

ព្រហ្មញ្ញសាសនាបានសម្តែងថា: សេចក្តីស្លាប់គឺជាការបែកធ្លាយតែរាងកាយ ឯអាត្ម័នពុំបានបែកធ្លាយទេ គឺអាត្ម័នត្រូវចេញពីរូបរាងកាយដែលបែកធ្លាយ ទៅរស់នៅក្នុងរូបរាងកាយថ្មីទៀត ។ នេះគឺជាការសម្តែងឡើងនូវការស្លាប់និងការកើតរបស់ព្រហ្មញ្ញសាសនា ។

ជាចម្លើយសរុបចំពោះសំនួរខាងលើ យើងអាចនិយាយបានថា ព្រះពុទ្ធសាសនា មិនបានសម្តែងអំពីជំនឿខាងព្រលឹងទេ គឺសម្តែងតែអំពីតំណនៃសង្ខតធម៌ជាធម៌ដែលមានបច្ច័យប្រជុំតាក់តែងតែប៉ុណ្ណោះ ។ ការកើតនិងរលត់តៗគ្នានេះ មិនមែនទើបតែមាននៅពេលស្លាប់នោះទេ គឺមានគ្រប់ខណៈ សូម្បីតែពេលកំពុងរស់នៅក៏ដោយ ។ ឯសាសនាដែលសម្តែងអំពីជំនឿព្រលឹងនោះ គឺព្រហ្មញ្ញសាសនា ។ សាសនាទាំងឡាយដទៃទៀត ក្នុងលោកនេះ ក៏មានទំនងនៃការសម្តែងអំពីជំនឿនេះដូចគ្នាដែរ ព្រោះមេដឹកនាំសាសនាទាំងនោះពុំបានដឹងអំពីដំណើរ នៃការប្រព្រឹត្តទៅនៃជីវិតដូចព្រះសម្មាសម្ពុទ្ធ ដែលទ្រង់បានត្រាស់ដឹងនូវសេចក្តីពិតនៃជីវិតនោះឡើយ ។

INTRODUCTION

The word "*Buddhaparisada*" (Buddhist) is the compound of two separate words, i.e. '*Buddha*' in the Pãli or Sanskrit language which means one who realizes hidden phenomena like The Four Noble Truths and so on up to the paths leading to cessation of sufferings, the fruits and nirvana or one who is awake –mindful and clearly conscious all the time or one who is fully blooming like a lotus flower blooming all its petals –his mind is blooming because of the power of holiness as all defilements are eradicated, called *The Fully Enlightened One, The Enlightened Being, The Supreme Teacher, The Lord,* etc. who is generally known as the founder of Buddhism, and the word '*Parisada*' in Sanskrit, '*Parisã*' for Pãli meaning

a group of people assembling together or a group of people approaching someone or a place. In combination as the word "*Buddhaparisada*" which means a group of people assembling together around The Enlightened Being or a group of people approaching The Fully Enlightened One.

In Buddhism *Buddhaparisadas* are of four kinds, i.e. the order of monks, the order of nuns, laymen and laywomen. In Cambodia, the word "*Buddhaparisadas*", we prefer to use to call lay followers of Buddhism, for the orders are rarely heard to be called *Buddhaparisadas*. In fact, we must be aware that the word "*Buddhaparisadas*" refers to both the orders and the lay-people –the orders consist of the order of monks and the order of nuns and the lay-people consist of laymen and laywomen.

Amongst the four *Buddhaparisadas* only two are to be described in this booklet, laymen and laywomen, because the order of monks and the order of nuns have so many rules and disciplines to practise. For laymen and laywomen, they also have rules and disciplines to practise, but in this booklet I will bring some points that I find important and useful to Buddhists to describe and add extra explanations through my own knowledge and additional research.

GENUINE BUDDHISTS

In *Anguttaranikãya Pañcakanipãta Chatthamabhãga* right in *Catutthapannãsaka Upãsakavagga* of the discourse scripture (Khmer scripture volume 45), the Buddha stated that:

"*Pañcahi bhikkhave dhammehi sammannãgato upãsako upãsakaratanañca hoti upãsakapadumañca upãsakapundarĩkañca.* O Bhikkhus, a layman who is endowed with five good qualities is called a '*ratanaupãsaka*', a '*padumaupãsaka*' and a '*pundarĩkaupãsaka*'. *Katamehi pañcahi?* What are the five good qualities? *Saddho hoti sĩlavã hoti akotuhalamangaliko hoti kammam pacceti no*

mangalam na ito bahiddhã dakkhineyyam gavesati idha ca pubbakãram karoti. A layman who is confident is one, a layman who is moral is one, a layman who does not adhere to superstitions is one, believes only in *kamma* (action) not in superstition is one, does not seek for one who is worthy of gifts outside Buddhism; does meritorious deeds only in Buddhism is one. *Imehi kho bhikkhave pañcahi dhammehi sammannãgato upãsako upãsakaratanañca hoti upãsakapadumañca upãsakapundarĩkañcãti.* O Bhikkhus, a layman who is endowed with five good qualities is called a '*ratanaupãsaka*', a '*padumaupãsaka*' and a '*pundarĩkaupãsaka*'."

According to the above-mentioned teachings, the Buddha called a layman who is endowed with five good qualities

a ‘*ratanaupãsaka’* (a layman like priceless jewels – gold and diamond and the like), a ‘*paduma-upãsaka’* (a layman like *paduma* –red lotus flower) and a ‘*pundarĩkaupãsaka’* (a layman like *pundarĩka* – white lotus flower).

The word “*Upãsaka”* here refers to lay followers of Buddhism, both layman and laywoman, like the explanation in *Ekasesasamãsa* (a compound which either part is left) of Pãli language which verifies that: ‘*Upãsako ca upãsikã ca = Upãsakã’* meaning both layman and laywoman as laymen.

In this booklet, may I use the word **“Genuine Buddhists”** instead of the three above words,

'ratanaupãsaka', 'padumaupãsaka' and *'pundarĩka-upãsaka'*, to make Buddhists understand clearly that to be **Genuine Buddhists** they must be the three above-mentioned *upãsakas* and to be the three above-mentioned *upãsakas* they must be *upãsaka* who is endowed with the five good qualities, i.e. as a layman who is confident and the rest.

1 A LAYMAN WHO IS CONFIDENT

The word "*Saddhã*" (confidence or faith) is a Pãli word. Its explanation is '*Saddhahatĩti = Saddhã*' meaning what always believes is called '*Saddhã*'. *Saddhã* has its criteria called '*Lakkhanãdicadukka*' (four defining devices) as follows:

1. *Saddahanalakkhanã:* consisting of faith in good object of mind as its characteristic.
2. *Pasãdanarasã:* consisting of clarity as its function.
3. *Akãlussiyapaccuppatthãnã:* consisting of non-turbidity and non-darkness as its exact aura.
4. *Saddheyyavatthupadatthãnã:* consisting of thing as the state of confidence as its closest cause.

